**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ : ៨១៩ មស.ក្រខ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៧

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ** ៖ ស្តីពីគោលការណ៍អនុញ្ញាតរំលឹកប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យាប្រើប្រាស់ជាក់ស្តែងសម្រាប់ខែមករា ខែកុម្ភៈ និងបើកផ្តល់ក្នុងខែមីនា ឆ្នាំ២០១៧។

**យោង** ៖
- អនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា
- អនុក្រឹត្យលេខ២៧៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការដំឡើងប្រាក់កម្រៃប្រចាំខែជូនមន្ត្រីជាប់កិច្ចសន្យា
- សារាចរលេខ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល
- លិខិតលេខ៩៩៥ មស.សណន ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការបើកផ្តល់ប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យា
- លិខិតលេខ៤៨៧ មស.ក្រខ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការផ្តល់ផែនការក្របខណ្ឌជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៧។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា ក្រសួងមុខងារសាធារណៈ ផ្តល់គោលការណ៍អនុញ្ញាតរំលឹកប្រាក់កម្រៃជូនមន្ត្រីជាប់កិច្ចសន្យាប្រើប្រាស់ជាក់ស្តែងសម្រាប់ខែមករា ខែកុម្ភៈ និងបើកផ្តល់ក្នុងខែមីនា ឆ្នាំ២០១៧ ជូនគ្រប់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងករណីមានការយឺតយ៉ាវក្នុងការបំពេញបែបបទ។

សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**
- សាលារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប"
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ផ្លូវវិថ្ងីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh